# តើការធ្វើសកម្មភាពដោយសេចក្ដីជំនឿមានន័យដូចម្ដេច ?

ឯកសារថ្នាក់សិក្ខាសាលាសម្រាប់ព្រះគម្ពីរសញ្ញាថ្មី

សូមអាន *ឯកសារគោលនៃចំណេះចំណានខាងគោលលទ្ធិ* ( ឆ្នាំ ២០២២ ) « ការទទួលបានចំណេះខាងវិញ្ញាណ » កថាខណ្ឌ ១–២ និង ៥–៧ និងសេចក្ដីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ នៅពេលអ្នកសិក្សា សូមរកមើលអត្ថន័យនៃការធ្វើសកម្មភាពដោយសេចក្ដីជំនឿ និងអ្វីដែលអាចជួយអ្នកឲ្យអនុវត្តគោលការណ៍នេះ នៅពេលអ្នកមានសំណួរ ។



សេចក្ដីជំនឿពុំមែនកើតមានចំពោះយើងដោយចៃដន្យ ឬនៅជាប់នឹងយើងដោយសារតែមរតករបស់បងប្អូនឡើយ ។ ... សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាអំណោយមួយពីស្ថានសួគ៌ដែលប្រទានមក នៅពេលយើងជ្រើសរើសដើម្បីជឿ និងនៅពេលយើងស្វះស្វែងរកវា ហើយតោងជាប់នឹងវា ។ អនាគតនៃសេចក្ដីជំនឿរបស់អ្នក គឺពុំមែនកើតមកពីភាពចៃដន្យនោះទេ ប៉ុន្តែមកពីជម្រើសវិញ ។

សេចក្ដីជំនឿពុំទាមទារនូវចម្លើយចំពោះគ្រប់សំណួរនោះទេ ប៉ុន្តែវាស្វែងរកការបញ្ជាក់ និងការលើកទឹកចិត្តឲ្យឈានឆ្ពោះទៅមុខ ទោះបីជាពេលខ្លះយើងអាចទទួលស្គាល់ថា « ខ្ញុំពុំចេះគ្រប់យ៉ាងនោះទេ ប៉ុន្តែខ្ញុំដឹងគ្រប់គ្រាន់ ដើម្បីបន្តដើរនៅលើផ្លូវនៃភាពជាសិស្ស » ។

ការបន្តជ្រមុជខ្លួនឯងនៅក្នុងមន្ទិលសង្ស័យឥតឈប់ឈរ នឹងធ្វើឲ្យសេចក្ដីជំនឿរបស់មនុស្សម្នាក់លើព្រះយេស៊ូវគ្រីស្ទ និងការស្ដារឡើងវិញទន់ខ្សោយ ដោយសារចម្លើយមកពីមនុស្សដែលមានជំនឿតិច និងមនុស្សដែលគ្មានជំនឿ ។ « មនុស្សខាងសាច់ឈាមគេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ » [ កូរិនថូស ទី១ ២:១៤ ] ។ ...

ទោះបីជាភ្លើងនៃសេចក្ដីជំនឿដំបូងរបស់អ្នក អាចមានតិចតួចក្ដី ជម្រើសសុចរិតនាំមកនូវទំនុកចិត្តកាន់តែខ្លាំងលើព្រះ ហើយសេចក្ដីជំនឿរបស់អ្នករីកចម្រើន ។ ( នែល អិល អាន់ឌើរសិន « សេចក្ដីជំនឿពុំមែនកើតមកពីភាពចៃដន្យនោះទេ ប៉ុន្តែមកពីជម្រើសវិញ » *Ensign* ឬ *Liahona*ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ៦៥–៦៧ )

- ហេតុអ្វីបានជាអ្នកគិតថា វាសំខាន់ដើម្បីធ្វើសកម្មភាពដោយសេចក្ដីជំនឿនៅពេលយើងមានសំណួរ និងកង្វល់នោះ ?
- តើអ្នកបានរៀនអ្វីខ្លះពីអត្ថបទអំណានទាំងនេះ អំពីអត្ថន័យនៃការធ្វើសកម្មភាពដោយសេចក្ដីជំនឿ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *What Does It Mean to Act in Faith?*
Cambodian ។ PD60012661 258 ។ Printed in the United States of America